ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គភាពស៊ើបការណ៍ ហិរញ្ញវត្ថុកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនសាធារណៈជន ឲ្យបានជ្រាបថានៅវេលាម៉ោង ១០ព្រឹក ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៦ នេះ អគ្គនាយកដ្ឋានពន្ធដារ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការ សម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ពិធីចុះហត្ថលេខានេះ ត្រូវបានចុះហត្ថលេខា ដោយឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងលោកជំទាវ **សាយ សំអាត** អគ្គលេខាធិការអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិ នៃកម្ពុជា។

អគ្គនាយកដ្ឋានពន្ធដារ ទទួលបានការផ្តល់ការឯកភាពជាគោលការណ៍ពី ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការចុះអនុស្សរណៈយោគយល់គ្នា រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៃធនាគារជាតិនៃកម្ពុជា ស្តីពីការផ្លាស់ប្តូរព័ត៌មាន ពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គឺក្នុងគោលបំណងធ្វើការផ្លាស់ប្តូរព័ត៌មាន រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៃធនាគារជាតិកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ សំដៅរួមគ្នាបង្កើនប្រសិទ្ធភាពស៊ើបអង្កេត លើករណីសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលអាចកើតចេញពីបទល្មើសនៃការគេចវេះពន្ធ និងក្នុងគោលដៅ ទទួលបាននូវលទ្ធផលជាវិជ្ជមាន អំពីការវាយ

តម្លៃអញ្ញមញ្ញ ពីសំណាក់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (Asia Pacific Group) មកលើព្រះរាជាណាចក្រកម្ពុជា។

ម្យ៉ាងទៀត អនុស្សរណៈនៃការយោគយល់គ្នានេះ គឺពិតជាមានសារសំខាន់ សម្រាប់អគ្គនាយកដ្ឋានពន្ធដារ ដែលជាអង្គភាពមួយ មានតួនាទីប្រមូលចំណូលពន្ធផ្ទៃក្នុងជូនជាតិ ព្រោះថា អគ្គនាយកដ្ឋានពន្ធដារ ត្រូវការជាចាំបាច់នូវព័ត៌មានហិរញ្ញវត្ថុរបស់អ្នកជាប់ពន្ធ សម្រាប់ជាមូលដ្ឋានក្នុងការគាំទ្រដល់កិច្ចការសវនកម្ម ក៏ដូចជាយន្តការក្នុងការអនុវត្តវិធានការតឹងទារបំណុលពន្ធ ពោលគឺការពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងសមភាព។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថាអនុស្សរណៈនៃការយោគយល់គ្នានេះ នឹងជាយន្តការដ៏មានសារសំខាន់ និងបំពេញឲ្យគ្នាទៅវិញទៅមក ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការផ្ទៃក្នុង ស្ដីពីការផ្លាស់ប្ដូរព័ត៌មានហិរញ្ញវត្ថុ ព័ត៌មានរបស់បុគ្គលឬអង្គភាព និងស្ថានភាពពាក់ព័ន្ធនឹងសកម្មភាពសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម ពាក់ព័ន្ធនឹងបទល្មើសគេចពន្ធ កេងបន្លំពន្ធ ដែលផលនៃបទល្មើសនេះ អាចត្រូវបានប្រើប្រាស់តាមរយៈប្រព័ន្ធហិរញ្ញវត្ថុ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ